

# ត្រៀមខ្លួនជាស្រេច។ បន្តទទួលការរ៉ាប់រង។

## កញ្ចប់ឧបករណ៍ទំនាក់ទំនងឌីជីថល

ជារៀងរាល់ឆ្នាំ រដ្ឋពិនិត្យមើលឡើងវិញនូវព័ត៌មានរបស់សមាជិកគម្រោង Medicaid ដើម្បីប្រាកដថាពួកគេនៅតែមានសិទ្ធិទទួលការរ៉ាប់រង។ ជាសំឡេងដែលគួរឱ្យទុកចិត្តនៅក្នុងសហគមន៍របស់អ្នក អ្នកអាចលើកទឹកចិត្តប្រជាពលរដ្ឋ Rhode Island ដែលមានសិទ្ធិឱ្យចាត់វិធានការដែលជួយពួកគេបន្តទទួលការរ៉ាប់រងពីគម្រោង Medicaid។ នៅក្នុងប្រអប់ឧបករណ៍នេះ អ្នកនឹងឃើញខ្លឹមសារបង្ហោះលើបណ្ដាញទំនាក់ទំនងសង្គមគំរូ និងព្រឹត្តិបត្រព័ត៌មានដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីការបន្តសុពលភាពគម្រោង Medicaid។ ការបកប្រែ និងធនធានមាននៅលើគេហទំព័រ staycovered.ri.gov/education-materials។

**សូមពិចារណាចែករំលែកសារទាំងនេះជាមួយបណ្ដាញរបស់អ្នក។ សូមអរគុណ។**

**ព្រឹត្តិបត្រព័ត៌មាន ឬ E-BLAST**



# តើអ្នកទទួលបានការរ៉ាប់រងពីគម្រោង Medicaid ដែរទេ?

## អ្វីដែលអ្នកត្រូវដឹងអំពីការបន្តការរ៉ាប់រងសុខភាពរបស់អ្នក។

ជារៀងរាល់ឆ្នាំ រដ្ឋពិនិត្យមើលឡើងវិញនូវព័ត៌មានរបស់សមាជិកគម្រោង Medicaid ដើម្បីប្រាកដថាពួកគេនៅតែមានសិទ្ធិទទួលបាន។ ប្រសិនបើយើងមានព័ត៌មានគ្រប់គ្រាន់ យើងនឹងផ្ញើជូនអ្នកនូវសេចក្តីជូនដំណឹង (សេចក្តីជូនដំណឹងអំពីការសម្រេចចិត្តផ្តល់អត្ថប្រយោជន៍) ដោយប្រាប់អ្នកថាយើងបានបន្តសុពលភាពគម្រោង Medicaid របស់អ្នក។

ប្រសិនបើយើងត្រូវការព័ត៌មានបន្ថែម **យើងនឹងផ្ញើជូនអ្នកនូវសេចក្តីជូនដំណឹងចំនួនពីរលិខិត៖**

**1** លិខិតជូនដំណឹងអំពីការបន្តសុពលភាពគម្រោង Medicaid ពណ៌លឿង។ **2** លិខិតជូនដំណឹងស្នើសុំឯកសារបន្ថែមពណ៌ស។

លិខិតជូនដំណឹងទាំងពីរនេះនឹងមកដល់ក្នុងសំបុត្រប្រៃសណីយ៍ដាច់ដោយឡែក។ ត្រូវប្រាកដថាអ្នករកមើលលិខិតទាំងពីរ។

## រឿង 3 យ៉ាងដែលអ្នកអាចធ្វើបានដើម្បីត្រៀមខ្លួនបន្តទទួលការរ៉ាប់រង។

1. **រក្សាបច្ចុប្បន្នភាពនៃព័ត៌មានគណនីរបស់អ្នក** ដូច្នេះរដ្ឋអាចទាក់ទងអ្នកជាមួយនឹងព័ត៌មានសំខាន់ៗបាន។ ឧទាហរណ៍ អ្នកគួរតែធ្វើបច្ចុប្បន្នភាពគណនីរបស់អ្នក ប្រសិនបើព័ត៌មានទំនាក់ទំនងរបស់អ្នកផ្លាស់ប្តូរ អ្នកទទួលបានការងារថ្មី ឬអ្នកមានកូន។

2. **រកមើលសំបុត្រប្រៃសណីយពីរដ្ឋ Rhode Island។** ប្រសិនបើកម្មវិធី Medicaid ត្រូវការព័ត៌មានបន្ថែម ដើម្បីបន្តការរ៉ាប់រងរបស់អ្នក អ្នកនឹងទទួលបានលិខិតជូនដំណឹងពណ៌លឿង។ អ្នកក៏នឹងទទួលបានលិខិតជូនដំណឹងស្នើសុំឯកសារបន្ថែមពណ៌សផងដែរ។ បើមិនដូច្នោះទេ អ្នកនឹងទទួលបានលិខិតជូនដំណឹងថា ការរ៉ាប់រងរបស់អ្នកបានបន្តដោយស្វ័យប្រវត្តិ។

3. **ចាត់វិធានការភ្លាមៗ។ ប្រសិនបើអ្នកទទួលបានលិខិតជូនដំណឹងពណ៌លឿង** វាមានន័យថារដ្ឋត្រូវការព័ត៌មានបន្ថែមអំពីអ្នក ឬមនុស្សក្នុងគ្រួសាររបស់អ្នក ដើម្បីបន្តការរ៉ាប់រងរបស់អ្នក។ សូមបញ្ជូនព័ត៌មានដែលបានស្នើសុំទាំងអស់ត្រឹមថ្ងៃផុតកំណត់នៅលើលិខិតជូនដំណឹងរបស់អ្នក។

## មានសំណួរដែរទេ?

**មានជំនួយ។ ទូរសព្ទ៖**

- HealthSource RI 1.855.840.4774
- ក្រសួងសេវាមនុស្សរដ្ឋ RI 1.855.697.4347

## គ្រប់គ្រងគណនីរបស់អ្នកតាមអនឡាញ៖

ចូលទៅកាន់គេហទំព័រ **healthyrhode.ri.gov** ឬដោយប្រើកម្មវិធីទូរសព្ទ HealthyRhode។ ដើម្បីស្វែងយល់បន្ថែមអំពីការបន្តសុពលភាពគម្រោង Medicaid ឬរកមើលនៅពេលដែលការបន្តសុពលភាពរបស់អ្នកនឹងធ្វើឡើង សូមចូលទៅកាន់គេហទំព័រ **staycovered.ri.gov**។



# បណ្ដាញទំនាក់ទំនងសង្គម

**RI Medicaid ចង់ធ្វើឲ្យប្រាកដថា អ្នក និងក្រុមគ្រួសាររបស់អ្នកទទួលបានព័ត៌មានសំខាន់ៗ** អំពីការរ៉ាប់រងសុខភាពរបស់អ្នក។ ធានាថា អាសយដ្ឋានរបស់អ្នកគឺជាអាសយដ្ឋានថ្មីចុងក្រោយ ហើយថាអ្នកបានអានអ្វីគ្រប់យ៉ាងដែលអ្នកទទួលបាននៅក្នុងសំបុត្រប្រៃសណីយ៍ពីរដ្ឋ Rhode Island ឬ Managed Care organization របស់អ្នក។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ **staycovered.ri.gov**។

**ប្រសិនបើអ្នកទទួលបានការរ៉ាប់រងសុខភាពតាមរយៈ Medicaid** អ្នកនឹងទទួលបានលិខិតជូនដំណឹងនៅក្នុងសំបុត្រប្រៃសណីយ៍ពីរដ្ឋ Rhode Island អំពីការបន្តការរ៉ាប់រងរបស់អ្នកជារៀងរាល់ឆ្នាំ។ ដើម្បីរកមើលកាលបរិច្ឆេទបន្តសុពលភាពរបស់អ្នក សូមចូលទៅកាន់គេហទំព័រ **staycovered.ri.gov**។

**ប្រសិនបើគ្រួសាររបស់អ្នកមានការរ៉ាប់រងសុខភាពតាមរយៈ Medicaid** អ្នកនឹងទទួលបានលិខិតជូនដំណឹងនៅក្នុងសំបុត្រប្រៃសណីយ៍អំពីការបន្តការរ៉ាប់រងរបស់អ្នកជារៀងរាល់ឆ្នាំ។ ចំពោះព័ត៌មានបន្ថែមជាច្រើនភាសា សូមចូលទៅកាន់គេហទំព័រ **staycovered.ri.gov**។

**សមាជិកគម្រោង Medicaid!** តើអ្នកមានការផ្លាស់ប្ដូរអាសយដ្ឋាន ប្រាក់ចំណូល ទំហំគ្រួសារ លេខទូរសព្ទ ឬអ៊ីមែលដែរទេ? អ្នកអាចធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកបានគ្រប់ពេលដោយចូលទៅកាន់គេហទំព័រ healthyrhode.ri.gov










